ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:.០០៥៩.....សហវ.សាចណ.

លិខិតចូល
ថ្ងៃទី..២៣...ខែ..មិថុនា..ឆ្នាំ២០០៦

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តន៍ប្រកាសស្តីពីការបន្តរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញពីរឆ្នាំ ចំពោះសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ

អនុវត្តតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គបើកទូលាយ កាលពីថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៣០២ សហវ.ប្រក.ពដ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការផ្តល់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញដល់សហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ពីរ (០២) ឆ្នាំបន្តទៀត ដោយចាប់គិតពីពេលដែលផុតសុពលភាពនៃរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញលើកមុន ។

យោងតាមការសម្រេចរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម :

១. សហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ គឺរួមមាន :

- រោងចក្រវាយនភ័ណ្ឌ
- រោងចក្រកាត់ដេរ និង
- រោងចក្រផលិតស្បែកជើង ។

២. សហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញដូចបានចែងក្នុងចំណុច១ខាងលើ ដែលត្រូវបានអនុញ្ញាតឱ្យផ្តល់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ពីរ (០២) ឆ្នាំបន្តទៀត គឺសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ដែលបានទទួលការសម្រេចអនុញ្ញាតឱ្យវិនិយោគនៅកម្ពុជា គិតត្រឹមថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៥ ហើយដែលផុតសុពលភាពនៃរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញលើកមុន ។

៣. សហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ដូចបានចែងក្នុងចំណុច១ខាងលើដែលបានទទួលការសម្រេចអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឱ្យវិនិយោគនៅក្រោយថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៥ ឬដែលបានទទួលការផ្តល់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញបន្តម្តងរួចហើយ មិនត្រូវបានអនុញ្ញាតឱ្យផ្តល់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ពីរ (០២) ឆ្នាំ ដូចបានចែងក្នុងចំណុច២ខាងលើនេះទេ ។

៤. ប្រសិនបើសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ដូចបានចែងក្នុងចំណុច១ខាងលើ បានបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនាក្រោយថ្ងៃផុតសុពលភាពនៃការលើកលែងពន្ធលើប្រាក់ចំណេញដំបូង ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនេះនឹងត្រូវបានអនុញ្ញាតជាឥណទានសម្រាប់កាត់កងនឹងប្រាក់រំដោះត្រូវបង់ក្រោយរយៈពេលលើកលែងបន្តពីរឆ្នាំត្រូវបានផុតសុពលភាព ។

៥. សហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ដូចបានចែងក្នុងចំណុច១ខាងលើ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យនាយកដ្ឋាននេះកំណត់កាលបរិច្ឆេទសម្រាប់ការលើកលែងពន្ធលើប្រាក់ចំណេញបន្ត ពីរ (០២) ឆ្នាំ ដូចមានចែងក្នុងចំណុច២ខាងលើនេះ ។

៦. សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៧ សហវ.ពដ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥ ត្រូវទុកជានិរាករណ៍ ។

៧. អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក លោកស្រី ជាអ្នកទទួលខុសត្រូវនៃសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរណែនាំនេះ ។/.

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន
- នាយកដ្ឋានពន្ធដារ
- ឯកសារ-កាលប្បវត្តិ